# សេចក្តីថ្លែងការណ៍រួម

## ជំរុញឱ្យរាជរដ្ឋាភិបាលកម្ពុជាផ្តល់សច្ចាប័នលើអនុសញ្ញា របស់អង្គការអន្តរជាតិខាងការងារ ស្តីពីអំពើហិង្សានិងការបៀតបៀននៅក្នុងពិភពការងារ ឆ្នាំ២០១៩ (អនុសញ្ញាលេខ១៩០)

ថ្ងៃនេះគឺជាថ្ងៃគម្រប់ខួប២ឆ្នាំនៃការអនុម័តអនុសញ្ញាលេខ១៩០ ស្តីពីអំពើហិង្សានិងការបៀតបៀន (អនុសញ្ញាលេខ១៩០) ។ នៅថ្ងៃទី ២១ ខែមិថុនាឆ្នាំ ២០១៩ គណៈប្រតិភូនៃរាជរដ្ឋាភិបាលកម្ពុជាបានចូលរួមជាមួយរដ្ឋាភិបាលនៃប្រទេសដទៃជាច្រើនទៀត តំណាងនិយោជក សហជីព និងអង្គការសង្គមស៊ីវិលមកពីជុំវិញពិភពលោក បានបោះឆ្នោតដើម្បីអនុម័តឱ្យមានអនុសញ្ញាលេខ១៩០ និងអនុសាសន៍លេខ ២០៦ របស់អង្គការអន្តរជាតិខាងការងារ នៅក្នុងសន្និសីទអន្តរជាតិស្តីពីការងារ ដែលប្រារព្ធនៅទីក្រុងហ្សឺណែវប្រទេសស្វីស។ ប្រទេសចំនួន ៦ បានផ្តល់សច្ចាប័នដល់អនុសញ្ញាលេខ១៩០ ដែលធ្វើឱ្យអនុសញ្ញានេះចូលជាធរមាននៅថ្ងៃទី ២៥ ខែមិថុនាឆ្នាំ ២០២១នេះ។ អនុសញ្ញាលេខ១៩០ គឺជាបទដ្ឋានការងារអន្តរជាតិដំបូងបង្អស់ដែលមានចំណងកាតព្វកិច្ចផ្លូវច្បាប់ដែលទទួលស្គាល់នូវសិទ្ធិក្នុងការទទួលបានពិភពការងារមួយដែលមិនមានអំពើហិង្សានិងការបៀតបៀនគ្រប់ប្រភេទ និងធានាថាកម្មករនិយោជិតទាំងអស់មានសិទ្ធិ ទទួលបាននូវការគោរពនិងសេចក្តីថ្លៃថ្នូរដោយមិនគិតពីឋានៈតួនាទី និងប្រភេទនៃកិច្ចសន្យាការងាររបស់ពួកគេ ទាំងវិស័យការងារក្នុងនិងក្រៅប្រព័ន្ធ។ អនុសញ្ញាលេខ១៩០ ទទួលស្គាល់ផងដែរនូវបរិបទនៃកន្លែងធ្វើការដែលគ្របដណ្តប់មិនត្រឹមតែកន្លែងធ្វើការផ្ទាល់ប៉ុណ្ណោះទេប៉ុន្តែរួមថែមទាំងការធ្វើដំណើរទៅមកកន្លែងធ្វើការ ការប្រាស្រ័យទាក់ទងនានាពាក់ព័ន្ធនឹងការងារ និងកន្លែងដែលកម្មករត្រូវបានគេផ្តល់ប្រាក់ឈ្នួល ម៉ោងឈប់សម្រាកឬសម្រាកញ៉ាំអាហាររបស់កម្មករនិយោជិត។

យើងខ្ញុំជំរុញឱ្យរដ្ឋាភិបាលធ្វើឱ្យឆ្នាំ ២០២១នេះ ជាឆ្នាំដែលប្រទេសកម្ពុជាចាត់វិធានការជាជំហានបន្ទាប់ដ៏សំខាន់ដើម្បីបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការបញ្ចប់អំពើហិង្សានិងការបៀតបៀនក្នុងពិភពការងាររួមទាំងអំពើហិង្សាផ្អែកលើយេនឌ័រនិងការបៀតបៀនផ្លូវភេទ។ គណៈកម្មាធិការនៃអង្គការសហប្រជាជាតិ សម្រាប់ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (ស៊ីដ) បានផ្តល់អនុសាសន៍ជាពិសេសដល់រដ្ឋាភិបាលកម្ពុជាដើម្បីផ្តល់សច្ចាប័នលើអនុសញ្ញាលេខ១៩០ នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ឆ្នាំ ២០១៩ របស់ខ្លួន បន្ទាប់ពី

ការពិនិត្យឡើងវិញនៃការអនុវត្តរបស់ប្រទេសកម្ពុជាលើអនុសញ្ញាស៊ីដ។ ការផ្តល់សច្ចាប័នលើអនុសញ្ញាលេខ១៩០នេះ មានន័យថា រដ្ឋាភិបាលនឹងឆ្លើយតបដោយជោគជ័យចំពោះសេចក្តីសន្និដ្ឋានបញ្ចប់របស់គណៈកម្មាធិការស៊ីដ។

គណៈកម្មាធិការបានសម្តែងការព្រួយបារម្ភបន្ថែមទៀតអំពីអវត្តមាននៃច្បាប់ដ៏ទូលំទូលាយមួយដែលកំណត់និងហាមឃាត់យ៉ាងមានប្រសិទ្ធភាពនូវអំពើហិង្សានិងការបៀតបៀនរួមទាំងការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ ជាពិសេសពិចារណាអំពីអត្រាកើនឡើងនៃអំពើហិង្សាបែបនេះនៅក្នុងឧស្សាហកម្មកាត់ដេរនិងពេលធ្វើដំណើរទៅនិងមកពីកន្លែងការងារ។ គណៈកម្មាធិការបានផ្តល់អនុសាសន៍ថារដ្ឋាភិបាលកម្ពុជា "អនុម័តនិងអនុវត្តច្បាប់ទូលំទូលាយដើម្បីការពារនិងឆ្លើយតបរាល់ទម្រង់នៃអំពើហិង្សានិងការបៀតបៀន រួមទាំងការបៀតបៀនផ្លូវភេទនៅក្នុងពិភពការងារនិងបង្កើតយន្តការបណ្តឹងឯករាជ្យដើម្បីធានាថាជនរងគ្រោះមានសិទ្ធិទទួលបាននូវការដោះស្រាយ ហើយជនល្មើសត្រូវតែទទួលខុសត្រូវ"។ ច្បាប់បែបនេះត្រូវការនិយមន័យច្បាស់លាស់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រនិងកាបៀតបៀនផ្លូវភេទរួមទាំងដំណើរការជាក់លាក់ដែលអនុលោមតាម បទដ្ឋានការងារអន្តរជាតិ។

ការផ្តល់សច្ចាប័នលើអនុសញ្ញាលេខ១៩០ គឺមានសារៈសំខាន់និងបន្ទាន់ជាងពេលណាៗទាំងអស់ ដែលអាចរួមចំណែកធ្វើឱ្យប្រទេសកម្ពុជាសម្រេចបាននូវរបៀបវារៈនៃការអភិវឌ្ឍប្រកបដោយចីរភាព ឆ្នាំ២០៣០ ជាពិសេសនៅក្នុងបរិបទនៃការឆ្លើយតបនិងការងើបឡើងវិញពីវិបត្តិកូវីដ១៩។ វិបត្តិកូវីដ១៩ បានធ្វើឱ្យស្ថានភាពការងាររបស់កម្មករនិយោជិតទាំងអស់កាន់តែធ្ងន់ធ្ងរឡើងរួមទាំងភាពអសន្តិសុខផ្នែកហិរញ្ញវត្ថុ ភាពអត់ការងារធ្វើ តានតឹងចិត្ត ការកើនឡើងនៃបន្ទុកការងារទៅលើស្ត្រីក្នុងការងារមើលថែទាំដែលគ្មានប្រាក់កម្រៃ និងការកើនឡើងនៃហានិភ័យនៃអំពើហិង្សាក្នុងគ្រួសារដែលប៉ះពាល់ដល់ការងារ។ អនុសញ្ញាលេខ ១៩០ និងអនុសាសន៍លេខ ២០៦ ផ្តល់នូវក្របខ័ណ្ឌច្បាប់ច្បាស់លាស់សម្រាប់វិធានការចាំបាច់ទាំងអស់ដើម្បីកំណត់គ្រោះថ្នាក់និងវាយតម្លៃហានិភ័យនៃអំពើហិង្សានិងការបៀតបៀននិងចាត់វិធានការប្រកបដោយប្រសិទ្ធភាពដើម្បីការពារសុវត្ថិភាពសុខភាពនិងសុខុមាលភាពរបស់កម្មករនិយោជិតទាំងអស់រួមទាំង បរិបទ កូវីដ១៩ ផងដែរ។

សេចក្តីថ្លែងការណ៍រួមនេះចូលរួមគាំទ្រដោយ៖

១. សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF)

២. សមាគមន៍ប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រពន្ធ័ (IDEA)

៣. អង្គការអាក់សិនអេតកម្ពុជា

៤. គណ:កម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី (NGO-CEDAW)

៥. មជ្ឈមណ្ឌលសាមគ្គីភាព (SC)

៦. អង្គការយែរអន្តរជាតិប្រចាំកម្ពុជា

៧. អង្គការក្លាហាន

៨. សហពន្ធ័សហជីពកម្ពុជា ( CATU )

៩. សីលកា

១០. មជ្ឈមណ្ឌលធនធានស្ត្រី (WRC)

១១. សមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា (CICA)

១២. សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា (CTWUF)

១៣. អង្គការយេនឌ័រនិងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)

១៤. បណ្តាញយេនឌ័រ (GADNet)

១៥. អង្គការសហគមន៍អភិឌ្ឍន៍មិត្តជនបទ (RFCD)

១៦. សហភាពការងារកម្ពុជា (CLC)

១៧. សហភាពចលនាកម្មករកម្ពុជា (CCWM)

១៨. សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា (FTUWKC)

១៩. អង្គការមជ្ឈមណ្ឌលសម្ពន្ធ័ភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់)

២០. សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៏ (LRSU)

២១. កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)

២២. អង្គការនារីដើម្បីសន្តិភាព (WPM)

២៣. សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា (BWTUC)

២៤. សហព័ន្ធសហជីពដើម្បីកម្មករ (TUFW)

២៥. សហព័ន្ធសហជីពជាតិនៃឧស្សាហកម្មវាយនភណ្ឌកាត់ដេរកម្ពុជា (NIFTUC)

២៦. សហព័ន្ធសហជីពមិត្តភាពកម្មករ (WFUF)

២៧. សហព័ន្ធសហជីពឯករាជ្យ (ITUF)

២៨. សហព័ន្ធសហជីពសេរីស្ត្រីកាត់ដេរ (CFTUWT)

២៩. សហព័ន្ធសហជីពដើម្បីកម្មករ (UCW)

៣០. សហព័ន្ធសហជីពការងារស្ត្រីកម្ពុជា (CWLUF)

៣១. សុខ លាំង, អ្នកស្រាវជ្រាវផ្នែកយេនឌ័រនិងសង្គមវិទ្យា

៣២. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នៅកម្ពុជា(ខុមហ្វ្រែល)

៣៣. អង្គការបណ្ដាញការងារស្ត្រីរួបរួមគ្នា (WNU)

៣៤. សមាគមអ្នកបម្រើការងារតាមផ្ទះ (ADW)

៣៥. សមាគមគាំពារស្ត្រីងាយរងគ្រោះ (ASVW)

៣៦. អង្គការបន្ទាយស្រី

៣៧. អង្គការកម្ពុជាដើម្បីសុខភាពនិងការអប់រំសហគមន៍ (CHEC)

៣៨. សមាគមថែទាំសុខភាពគ្រួសារកម្ពុជា (RHAC)

៣៩. ក្រុមសន្សំប្រាក់នារី (LSG)

៤០. អង្គការជំនួយផ្នែកច្បាប់ដល់កុមារ និងស្ត្រី (LSCW)

៤១. អង្គការសកម្មភាពសង្គមដើម្បីសហគមន៍និងការអភិវឌ្ឍ (SACD)

៤២.អង្គការអភិវឌ្ឍស្ត្រីក្រីក្រក្នុងទីក្រុង (UPWD)